ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

គណៈកម្មការរៀបចំមហោស្រព

សិល្បៈកំណាព្យ និងចម្រៀងខ្មែរជាសាកល

លេខ....៦៨....សវណ........

រាជធានីភ្នំពេញ, ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៦

សេចក្តីជូនដំណឹង

ស្តីពីការរៀបចំមហោស្រពសិល្បៈកំណាព្យ និងចម្រៀងខ្មែរជាសាកល លើកទី៤ ឆ្នាំ២០១៦ សម្រាប់បងប្អូនប្រជាពលរដ្ឋខ្មែរ ដែលរស់នៅក្រៅប្រទេស

****

ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ មានកិត្តិយសសូមជម្រាបជូនដំណឹងដល់បងប្អូនប្រជាពលរដ្ឋខ្មែរ ដែលរស់នៅក្រៅប្រទេសឱ្យបានជ្រាបថា ដើម្បីរួមចំណែកលើកស្ទួយវិស័យសិល្បៈវប្បធម៌ជាតិ ក្រសួងនឹងរៀបចំមហោស្រពសិល្បៈកំណាព្យ និងចម្រៀងខ្មែរជាសាកល លើកទី៤ ដែលនឹងប្រព្រឹត្តទៅចាប់ពីថ្ងៃទី១៧ ខែវិច្ឆិកា ដល់ថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០១៦ នៅរាជធានីភ្នំពេញ ដោយមានការចូលរួមពីបេក្ខជន-បេក្ខនារីមកពីរាជធានី-ខេត្ត ក្នុងព្រះរាជាណាចក្រកម្ពុជា និងបេក្ខជន-បេក្ខនារីខ្មែរដែលរស់នៅក្រៅប្រទេស ។

ក. វិញ្ញាសាប្រឡង

វិញ្ញាសាប្រឡងនៅក្នុងមហោស្រពនេះ មាន៤ប្រភេទគឺ ៖

១. សូត្រ ឬស្មូតកំណាព្យខ្មែរ

- ជ្រើសរើសបទកំណាព្យចំនួន៤បទ ក្នុងចំណោមបទដែលគណៈកម្មការបានកំណត់។
- សូត្រមិនលើសពី១០ល្បះ និងស្មូតមិនលើសពី៤ល្បះ។

២. ចម្រៀងប្រពៃណី (ភ្លេងការ)

- ជ្រើសរើសបទចម្រៀងភ្លេងការចំនួន៤បទ ក្នុងចំណោមបទដែលគណៈកម្មការបានកំណត់។

៣. ចម្រៀងបាសាក់

- ជ្រើសរើសបទចម្រៀងក្នុងទម្រង់ល្ខោនបាសាក់ចំនួន៤បទ ក្នុងចំណោមបទដែលគណៈកម្មការបានកំណត់។

៤. ចម្រៀងសម័យ

- ជ្រើសរើសយកបទចម្រៀងខ្មែរក្នុងទសវត្សរ៍ទី៥០ដល់៧០ ចំនួន០៤បទ ដែលមានចុងជួនរបៀបកំណាព្យខ្មែរ(មិនឌីជេ) តាមចង្វាក់ណាមួយនៃចង្វាក់ Slow, Slow Rock, Boléro Lent, Boléro , Cha Cha Cha, Jerk, Madison, Tango, Twist ។

ខ. លក្ខខណ្ឌនៃការដាក់ពាក្យប្រឡង

- មានអាយុចាប់ពី ១៨ឆ្នាំឡើងទៅ
- មានសញ្ជាតិដើមជាខ្មែរ ឬមានឪពុក ឬម្តាយមានសញ្ជាតិដើមជាខ្មែរ

- ពុំមែនជាជ័យលាភីលេខ១ នៃមហោស្រពប្រឡងចម្រៀងខ្មែរជាសាកល ពីលើកមុនៗ
- ត្រូវបំពេញពាក្យសុំប្រឡងចម្រៀង (ឯកសារភ្ជាប់ជូនភ្ជាប់)
- ត្រូវផ្ញើពាក្យសុំប្រឡង, បទចម្រៀង ឬកំណាព្យ ចំនួន២បទ (ថតសំឡេងច្រៀងផ្ទាល់ខ្លួន ដោយមិនចាំបាច់មានភ្លេង)ឱ្យបានមុនថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៦ មកក្រសួងវប្បធម៌និងវិចិត្រសិល្បៈ តាមអាសយដ្ឋាន៖ No.227, Sangkat Tonle Bassac, Khan Chamkar Mon, Phnom Penh, Cambodia ឬតាម Email: songcontest@mcfa.gov.kh ឬ yuntheara@gmail.com ដើម្បីឱ្យគណៈមេប្រយោគវាយតម្លៃ និងសម្រេចជ្រើសរើសបញ្ចូលក្នុងបញ្ជីសម្រាំងៗ
- បេក្ខជន-បេក្ខនារី ដែលជាប់ក្នុងបញ្ជីសម្រាំង ត្រូវផ្ញើបទចម្រៀង ឬកំណាព្យ ចំនួន២បទ (ថតសំឡេងច្រៀងផ្ទាល់ខ្លួនជាមួយនឹងបទភ្លេង-ចំពោះកំណាព្យមិនបាច់មានភ្លេង)ឱ្យបានមុនថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៦ មកក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ដើម្បីឱ្យគណៈមេប្រយោគវាយតម្លៃ និងសម្រេចជ្រើសរើសបញ្ចូលក្នុងបញ្ជីផ្តាច់ព្រ័ត្រៗ

គ . បេក្ខជន-បេក្ខនារី ដែលជាប់ក្នុងបញ្ជីផ្តាច់ព្រ័ត្រ (final list)

បេក្ខជន-បេក្ខនារី ដែលជាប់ក្នុងបញ្ជីផ្តាច់ព្រ័ត្រ នឹងទទួលបានការអញ្ជើញមកប្រទេសកម្ពុជា (ពីថ្ងៃទី២៣ ខែវិច្ឆិកា ដល់ថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០១៦) ដើម្បីចូលរួមប្រឡងនៅក្នុងមហោស្រពថ្នាក់ជាតិ នៅរាជធានីភ្នំពេញ ដោយទទួលបាន៖

- សំបុត្រយន្តហោះទៅ-មក
- សោហ៊ុយស្នាក់នៅ និងហូបចុក ។

ឃ . រង្វាន់ជ័យលាភី

បេក្ខជន-បេក្ខនារី ដែលឈ្នះការប្រកួតក្នុងមហោស្រពថ្នាក់ជាតិ នៅរាជធានីភ្នំពេញនឹងទទួលបាន -ពានរង្វាន់ចម្រៀងខ្មែរជាសាកល- ដូចខាងក្រោម៖

- ជ័យលាភីលេខ ១ ៖ ពាន អមដោយវិញ្ញាបនបត្រ និងថវិកាចំនួន ២០០០ ដុល្លារអាមេរិក
- ជ័យលាភីលេខ ២ ៖ ពាន អមដោយវិញ្ញាបនបត្រ និងថវិកាចំនួន ១៦០០ ដុល្លារអាមេរិក
- ជ័យលាភីលេខ ៣ ៖ ពាន អមដោយវិញ្ញាបនបត្រ និងថវិកាចំនួន ១២០០ ដុល្លារអាមេរិក
- រង្វាន់លួងចិត្តសម្រាប់អ្នកជាប់លេខ ៤ ៖ វិញ្ញាបនបត្រ និងថវិកាចំនួន ៨០០ ដុល្លារអាមេរិក
- រង្វាន់លួងចិត្តសម្រាប់អ្នកជាប់លេខ ៥ ៖ វិញ្ញាបនបត្រ និងថវិកាចំនួន ៥០០ ដុល្លារអាមេរិក

•ជូនភ្ជាប់ជាមួយនូវបញ្ជីបទកំណាព្យ បទចម្រៀងភ្លេងការ និងបទចម្រៀងបាសាក់ ដែលគណៈកម្មការកំណត់ៗ

<u>ព័ត៌មានបន្ថែមតាមរយៈ:</u>

Email: - songcontest@mcfa.gov.kh
- yuntheara@gmail.com /
- chankanha2012@gmail.com

Facebook: facebook.com/KhmerSongContest

(មហោស្រពសិល្បៈកំណាព្យនិងចម្រៀងខ្មែរជាសាកល)

រដ្ឋមន្ត្រី

និងជាប្រធានគណៈកម្មការអន្តរក្រសួង

ភឿង - សកុណា

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ
គណៈកម្មការអន្តរក្រសួងរៀបចំមហោស្រព
សិល្បៈកំណាព្យ និងចម្រៀងខ្មែរជាសាកល

លេខ......៤៧......ស.ជ.ណ.១៧

សេចក្តីជូនដំណឹង

ស្តីពី

ការរៀបចំមហោស្រពសិល្បៈកំណាព្យ និងចម្រៀងខ្មែរជាសាកល លើកទី៤ ឆ្នាំ២០១៦

យោងលិខិតលេខ ១២៥៦សជណ.អវ ចុះថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០១៥ របស់ទីស្តីការគណៈរដ្ឋមន្ត្រី រាជរដ្ឋាភិបាលបានប្រគល់ភារកិច្ចឲ្យក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ដោយសហការជាមួយធនាគារកាណាឌីយ៉ា ស្ថានីយទូរទស្សន៍បាយ័ន និងក្រសួង-ស្ថាប័នពាក់ព័ន្ធ បន្តរៀបចំមហោស្រពសិល្បៈកំណាព្យ និងចម្រៀងខ្មែរជាសាកល ដែលនឹងប្រព្រឹត្តទៅចាប់ពីពាក់កណ្តាលខែវិច្ឆិកា ដល់ដើមខែធ្នូ ឆ្នាំ២០១៦ សំដៅពង្រឹងស្មារតីចូលរួមថែរក្សា ការពារ និងលើកស្ទួយសិល្បៈកំណាព្យ និងចម្រៀងខ្មែរឲ្យបានស្ថិតស្ថេរជាអមតក្នុងបេះដូងកូនខ្មែរគ្រប់ៗរូប។ តាមស្មារតីនេះ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ សូមជម្រាបជូនដំណឹងដល់ គណៈកម្មការរៀបចំមហោស្រពថ្នាក់រាជធានី-ខេត្ត ស្ថានឯកអគ្គរាជទូត អគ្គកុងស៊ុល នៃព្រះរាជាណាចក្រកម្ពុជាប្រចាំនៅបរទេស សមាគម និងសហគមន៍ខ្មែររស់នៅបរទេស ព្រមទាំងសាធារណជនខ្មែរទាំងក្នុង និងក្រៅប្រទេស ឲ្យបានជ្រាបពីលក្ខខណ្ឌនៃការចូលរួមប្រឡងក្នុងមហោស្រពសិល្បៈកំណាព្យ និងចម្រៀងខ្មែរជាសាកល នេះ ដូចខាងក្រោម ៖

១. លក្ខណសម្បត្តិនៃបេក្ខជន បេក្ខនារី

ពលរដ្ឋទាំង២ភេទ ត្រូវ៖

- មានអាយុចាប់ពី១៨ឆ្នាំឡើងទៅ
- មានសញ្ជាតិដើមជាខ្មែរ ឬមានឪពុក ឬម្តាយ មានសញ្ជាតិដើមជាខ្មែរ
- ស្ម័គ្រចិត្តចូលរួមច្រៀងម្តងម្កាលពេលអាជ្ញាធរមានសមត្ថកិច្ចសំណូមពរ
- ពុំមែនជាជ័យលាភីលេខ១ នៃមហោស្រពប្រឡងសិល្បៈចម្រៀងខ្មែរជាសាកល ពីលើកមុនៗ។

២. ការដាក់ពាក្យប្រឡង

បេក្ខជន-បេក្ខនារី ដែលមានលក្ខណសម្បត្តិដូចក្នុងចំណុច១ខាងលើ មានសិទ្ធិដាក់ពាក្យចូលរួមប្រឡង ចាប់ពីថ្ងៃជូនដំណឹងនេះទៅ៖

២.១. បេក្ខជន-បេក្ខនារីនៅក្នុងប្រទេស

- អាចដាក់ពាក្យសុំចូលរួមប្រឡង(តាមគំរូពាក្យសុំ) នៅតាមមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈរាជធានី-ខេត្ត ដែលសាមីខ្លួនកំពុងរស់នៅ។

២.២. បេក្ខជន-បេក្ខនារីនៅបរទេស

- អាចដាក់ពាក្យសុំចូលរួមប្រឡង(តាមគំរូពាក្យសុំ) នៅលើគេហទំព័រ "www.mcfa.gov.kh" ឬតាម Facebook របស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ឬនៅតាមស្ថានឯកអគ្គរាជទូត អគ្គកុងស៊ុលនៃរដ្ឋដែលសាមីខ្លួនកំពុងរស់នៅ។

៣. អំពីវិញ្ញាសាប្រឡង

៣.១. កំណាព្យ (ផ្នែកសូត្រ ឬស្មូតកំណាព្យខ្មែរ)

- បេក្ខជន-បេក្ខនារី ត្រូវសូត្រ មិនលើសពី១០ល្បះ និងស្មូតមិនលើសពី៤ល្បះ។

៣.២. ចម្រៀងប្រពៃណី (ភ្លេងការ)

- បេក្ខជន-បេក្ខនារី ត្រូវជ្រើសរើសបទចម្រៀងប្រពៃណី(បទភ្លេងការ)ចំនួន២បទ ក្នុងចំណោមបទចម្រៀងដែលគណៈកម្មការបានផ្សព្វផ្សាយជូន។

៣.៣. ចម្រៀងល្ខោនបាសាក់

- បេក្ខជន-បេក្ខនារី ត្រូវជ្រើសរើសបទចម្រៀងក្នុងទម្រង់ល្ខោនបាសាក់ចំនួន២បទ ក្នុងចំណោមបទចម្រៀងដែលគណៈកម្មការបានផ្សព្វផ្សាយជូន។

៣.៤. ចម្រៀងសម័យទំនើប

- ដោយឡែកបទចម្រៀងសម័យទំនើប ត្រូវជ្រើសរើសយកបទចម្រៀងនៅក្នុងទសវត្សរ៍ទី៥០ ដល់ទី៧០ ចំនួន០២បទ ដែលមានចុងជួនរបៀបកំណាព្យខ្មែរ(មិនរីដ) តាមចង្វាក់ណាមួយនៃចង្វាក់ Slow, Slow Rock, Boléro Lent, Boléro , Cha Cha Cha, Jerk, Madison, Tango, Twist។

៤. អំពីកាលបរិច្ឆេទប្រឡង

៤.១- បេក្ខជន-បេក្ខនារី នៅក្នុងប្រទេស

- គណៈកម្មការថ្នាក់រាជធានី-ខេត្ត ត្រូវរៀបចំប្រឡងផ្តាច់ព្រ័ត្រផ្នែកសូត្រ ឬស្មូតកំណាព្យ ចម្រៀងប្រពៃណី ចម្រៀងល្ខោនបាសាក់ និងចម្រៀងសម័យ ឲ្យបានមុនថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៦។
- គណៈកម្មការថ្នាក់រាជធានី-ខេត្ត ត្រូវបញ្ជូនសំណុំឯកសារពាក្យសុំប្រឡង និងស៊ីឌីបទចម្រៀង កំណាព្យរបស់បេក្ខជន-បេក្ខនារី ជាជ័យលាភីលេខ១ (ផ្នែកសូត្រ ឬស្មូតកំណាព្យ ចម្រៀងប្រពៃណី ចម្រៀងល្ខោនបាសាក់ និងចម្រៀងសម័យ)ដែលត្រូវចូលរួមប្រឡងនៅមហោស្រពថ្នាក់ជាតិ មកលេខាធិការដ្ឋានអចិន្ត្រៃយ៍នៃគណៈកម្មការអន្តរក្រសួង ឲ្យបានមុនថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៦។
- គណៈកម្មការថ្នាក់រាជធានី-ខេត្ត ត្រូវបញ្ជូនបេក្ខជន-បេក្ខនារី ដែលជាប់ជ័យលាភីលេខ១ទាំងអស់ឡើងមកដល់ភ្នំពេញ នៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៦ ដើម្បីចូលរួមការប្រឡងនៅថ្ងៃបន្ទាប់។

៤.២- បេក្ខជន-បេក្ខនារី នៅបរទេស

- ចំពោះបេក្ខជន-បេក្ខនារីនៅបរទេស ត្រូវផ្ញើពាក្យសុំប្រឡង បទចម្រៀងឬកំណាព្យ ចំនួន២បទ (ជាសំនៀងផ្ទាល់ខ្លួន មិនចាំបាច់មានភ្លេង) មកលេខាធិការដ្ឋានអចិន្ត្រៃយ៍នៃគណៈកម្មការអន្តរក្រសួង តាមរយៈគេហទំព័រ ឬ Facebook របស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ឬបញ្ជូនសំណុំឯកសារពាក្យសុំប្រឡង និងស៊ីឌីបទចម្រៀង ឬកំណាព្យនេះ តាមរយៈស្ថានឯកអគ្គរាជទូត អគ្គកុងស៊ុល នៃរដ្ឋដែលសាមីខ្លួនកំពុងរស់នៅ ឲ្យបានមុនថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៦ ដើម្បីឲ្យគណៈមេប្រយោគនៃគណៈកម្មការអន្តរក្រសួង ពិនិត្យ វាយតម្លៃ និងសម្រេចជ្រើសរើសបញ្ចូលក្នុងបញ្ជីសម្រាំង។
- បេក្ខជន-បេក្ខនារី ដែលត្រូវបានគណៈមេប្រយោគជ្រើសរើសបញ្ចូលក្នុងបញ្ជីសម្រាំង ត្រូវផ្ញើបទចម្រៀង ឬកំណាព្យ ចំនួន២បទ (ជាសំនៀងផ្ទាល់ខ្លួនជាមួយនឹងបទភ្លេង) មកលេខាធិការដ្ឋានអចិន្ត្រៃយ៍នៃគណៈកម្មការអន្តរក្រសួង ឲ្យបានមុនថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៦ ដើម្បីឲ្យគណៈមេប្រយោគពិនិត្យ វាយតម្លៃ និងសម្រេចជ្រើសរើសបញ្ចូលក្នុងបញ្ជីផ្តាច់ព្រ័ត្រ។

- បេក្ខជន-បេក្ខនារី ដែលត្រូវបានគណៈមេប្រយោគសម្រេចបញ្ចូលក្នុងបញ្ជីផ្តាច់ព្រ័ត្រ ត្រូវមកដល់ភ្នំពេញ នៅថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ ដើម្បីមកចូលរួមប្រឡងនៅក្នុងមហោស្រពថ្នាក់ជាតិ។

៤.៥- កម្មវិធីបើកមហោស្រពថ្នាក់ជាតិ និងប្រព្រឹត្តទៅនាថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១៦ និងបិទនាថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០១៦ នៅរាជធានីភ្នំពេញ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមគណៈកម្មការរៀបចំមហោស្រពថ្នាក់រាជធានី-ខេត្ត ស្ថានឯកអគ្គរាជទូត អគ្គកុងស៊ុលនៃព្រះរាជាណាចក្រកម្ពុជាប្រចាំនៅបរទេស សមាគម និងសហគមន៍ខ្មែររស់នៅក្រៅប្រទេស មេត្តាជ្រាបជាព័ត៌មាន ព្រមទាំងសាធារណជន សិល្បករ សិល្បការិនី និងអ្នកស្រឡាញ់ចូលចិត្តវិស័យសិល្បៈ ដែលមានបំណងចូលរួមប្រឡងក្នុងមហោស្រពនេះ សូមទំនាក់ទំនងដាក់ពាក្យសុំប្រឡងតាមអាសយដ្ឋាន និងកម្មវិធី ដូចបានជម្រាបជូនខាងលើ តាមការគួរ ។

- ជូនភ្ជាប់នូវបញ្ជីបទចម្រៀងប្រពៃណី និង បទចម្រៀងល្ខោនបាសាក់ ចំនួន១ច្បាប់។

រាជធានីភ្នំពេញ, ថ្ងៃទី២៩ ខែ៨ ឆ្នាំ២០១៦

រដ្ឋមន្ត្រី

និងជាប្រធានគណៈកម្មការអន្តរក្រសួង

ភឿង - សកុណា

ព័ត៌មានលម្អិតសូមទាក់ទងតាមរយៈ៖

- លោក យន់ ធារ៉ា, Tel: +855(0)12 842 270, E-mail: yuntheara@gmail.com
- លោកស្រី ចាន់ កញ្ញា, Tel: +855(0)12 900 163, E-mail: chankanha2012@gmail.com

អាសយដ្ឋាន៖ ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ លេខ២២៧ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ
Email: info@mcfa.gov.kh, Website: www.mcfa.gov.kh

គណៈកម្មការអន្តរក្រសួង
រៀបចំមហោស្រពសិល្បៈគំនូរ
និងបង្រៀនខ្មែរជាសាកល

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រូបថត

៤ X ៦

ជីវប្រវត្តិ
CURRICULUM VITAE

I. ជីវប្រវត្តិផ្ទាល់ខ្លួន DETAIL BACKGROUND

Surname First name

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ (អក្សរខ្មែរ និងអក្សរឡាតាំង)
Full Name (Khmer and English) in block letters ____________________

នៅលីវ Single ☐ ឬ or មានគ្រួសារ Married ☐ ភេទ : ប្រុស Sex : Male ☐ ស្រី Female ☐

សញ្ជាតិដើម Ethnicity ______ សញ្ជាតិ Nationality ______ ថ្ងៃខែឆ្នាំកំណើត Date of Birth ______

ទីកន្លែងកំណើត Place of Birth ____________________

ទីលំនៅបច្ចុប្បន្ន Current Address ____________________

មុខរបរសព្វថ្ងៃ Current Employment ______ Tel: ______ E-mail: ______

II. ស្ថានភាពគ្រួសារ FAMILY STATUS

ឪពុកឈ្មោះ Father's name ______ ឆ្នាំកំណើត Year of Birth ______ សញ្ជាតិដើម Ethnicity ______

សញ្ជាតិ Nationality ______ ស្លាប់ Decease ☐ រស់ Alive ☐ មុខរបរ Career ______

ម្តាយឈ្មោះ Mother's name ______ ឆ្នាំកំណើត Year of Birth ______ សញ្ជាតិដើម Ethnicity ______

សញ្ជាតិ Nationality ______ ស្លាប់ Decease ☐ រស់ Alive ☐ មុខរបរ Career ______

ទីលំនៅបច្ចុប្បន្ន Current Address ____________________

ខ្ញុំបាទ/នាងខ្ញុំសូមអះអាងថា សេចក្តីរៀបរាប់ក្នុងជីវប្រវត្តិខាងលើនេះ ពិតជាត្រឹមត្រូវឥតក្លែងបន្លំឡើយ។ ប្រសិនបើមានចំណុចណាមួយដែលប្រាសចាកពីការពិត ខ្ញុំបាទ/នាងខ្ញុំសូមទទួលខុសត្រូវចំពោះមុខច្បាប់ជាធរមាន។

I declare that all information provided by in this application is accurate according to my knowledge. I am aware that if deliberately conveyed wrong information or mislead, I will be accountable under the law of the Kingdom of Cambodia.

ធ្វើនៅ ថ្ងៃទី ខែ ឆ្នាំ
Place, Date ____________________

ហត្ថលេខាសាមីខ្លួន
Signature of Applicant

គណៈកម្មការអន្តរក្រសួង
រៀបចំមហោស្រពសិល្បៈកំណាព្យ
និងចម្រៀងខ្មែរជាសាកល

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រូបថត

៤ X ៦

ពាក្យសុំប្រឡងចម្រៀង
APPLICATION FORM

Surname First name

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ(អក្សរខ្មែរ និងអក្សរឡាតាំង)
Full Name (Khmer and English) in block letters

នៅលីវ ☐ ឬ មានគ្រួសារ ☐ ភេទ : ប្រុស ☐ ស្រី ☐
Single or Married Sex : Male Female

សញ្ជាតិដើម Ethnicity ______ សញ្ជាតិ Nationality ______ ថ្ងៃខែឆ្នាំកំណើត Date of Birth ______

ទីលំនៅបច្ចុប្បន្ន : Current Address ភូមិ Village ______ ឃុំ/សង្កាត់ Commune/Sangkat ______

ស្រុក/ខណ្ឌ District/Khan ______ រាជធានី/ខេត្ត Capital City/Province ______

មុខរបរសព្វថ្ងៃ Current Employment ______

<u>សូមគោរពជូន</u>

To

លោកជំទាវ ប្រធានគណៈកម្មការអន្តរក្រសួងរៀបចំមហោស្រពសិល្បៈកំណាព្យ និងចម្រៀងខ្មែរជាសាកល

The President of Inter-Ministerial Committee for competition of Poetry and Universal Khmer Song Festival

ខ្ញុំបាទ/នាងខ្ញុំ សូមជម្រាបជូនលោកជំទាវប្រធានមេត្តាជ្រាបថា ខ្ញុំបាទ/នាងខ្ញុំ សុំចុះឈ្មោះចូលរួមប្រឡងចម្រៀង៖

I would like to register for song Contest in the following Context:

សូត្រ/ស្មូតកំណាព្យ Poetry song ☐ ចម្រៀងប្រពៃណី Wedding song ☐ ចម្រៀងបាសាក់ Bassac song ☐ ចម្រៀងសម័យ Modern song ☐

ឈ្មោះបទចម្រៀង Title of the song ______ ចង្វាក់ Rhythm ______

ធ្វើនៅ ថ្ងៃទី ខែ ឆ្នាំ Place, Date ______

ហត្ថលេខាសាមីខ្លួន
Signature of Applicant

បទចម្រៀងប្រពៃណី(ភ្លេងការ)ដែលមានអាទិភាព

ល.រ	ឈ្មោះបទ	ល.រ	ឈ្មោះបទ	ល.រ	ឈ្មោះបទ
១	នគររាជ	២	នគររាជជើងព្រៃ	៣	ផ្ទុមនាង
៤	បន្ទាយប្រាសាទ	៥	ស្តេចផ្ទុំ	៦	សារ៉ាយអណ្តែត
៧	ស្វាយក្នុងវត្ត	៨	នាគព័ន្ធ	៩	សំពោង
១០	ព្រះថោង	១១	នាងនាគ	១២	ផាត់ជាយ
១៣	ចោលចាប	១៤	កាត់ត្រើយ	១៥	កន្សែងក្រហម(ស្គូត្រ)
១៦	បង្គងក្អែក	១៧	កិន្នរ	១៨	ជាយកន្សែង
១៩	ជុំគ្រែ	២០	បណ្តែតកន្ទោង	២១	សំពោង
២២	ចាន់ទ្រលាំ	២៣	អន្ទាក់ព្រៃទ្រ	៣៤	ផាត់ជាយក្លាយ
២៥	ចំបក់ពោយ	២៦	ក្លងបណ្តែត	២៧	ស្រីស្រងាំ
២៨	ស្រីអ៊ុក	២៩	ក្លោងធំ	៣០	ស្រីស្ងួត

បទចម្រៀងបាសាក់ដែលមានអាទិភាព

ល.រ	ឈ្មោះបទ	អត្ថប្រយោជន៍	ល.រ	ឈ្មោះបទ	អត្ថប្រយោជន៍
១	នគររាជ	កំសត់ខ្លាំង	២	នគររាជជើងព្រៃ	កំសត់ខ្លាំង
៣	លោមតឹង	រៀបរាប់	៤	លោមធូរ	ស្នេហា
៥	លោមស្មើ	រៀបរាប់,កំសត់មធ្យម	៦	លោមចំហៀង	កំសត់មធ្យម
៧	លោមញាប់	តួយក្សរៀបរាប់	៨	សំពោង	កំសត់មធ្យម
៩	ផាត់ជាយ	រៀបរាប់,ខឹងមធ្យម	១០	ផាត់ជាយយក្ស	តួយក្សរៀបរាប់,ខឹង
១១	ស្រីខឹង	តួស្រីខឹងខ្លាំង	១២	កនឆារ	តួស្រីខឹងខ្លាំង
១៣	ទំនួញបារាំង	កំសត់ខ្លាំង	១៤	បំពេទី១	បំពេ តួឯក,ស្តេច
១៥	ទំនួញបាសាក់	កំសត់ខ្លាំង	១៦	រ៉ាំងណាំ	ខឹងខ្លាំង
១៧	រ៉ាំងចែកទ័ព	ស្វាហាប់,បញ្ជាទ័ព	១៨	រ៉ាំងហុកគៀន	ខឹងខ្លាំង
១៩	រ៉ាំងចែកទ័ពក្លាយ	ស្វាហាប់,បញ្ជាទ័ព	២០	សាំងសាលីវ	ខឹងមធ្យម
២១	រ៉ាំងលើកទ័ព ឬរ៉ាំងខិ	ស្វាហាប់,បញ្ជាទ័ព	២២	រ៉ាំងឯកោ	ខឹងខ្លាំង
២៣	រ៉ាំងយង់ហ្គោឬរ៉ាំងកាតាំង	តួកាច កំសត់	២៤	ណាងគ្រួន	ឥទ្ធិពលមហោរី
២៥	ប្រែប្រាណ(ឱរ៉ាសាគរ)	ឥទ្ធិពលមហោរី	២៦	ស៊ុរិយ៉ន(ស៊ុរិយុង)	រៀបរាប់ព្រៃ
២៧	ពាក្យប្រាំពីរ	ផ្ញើអក្ខរា	២៨	ចំពីកើច	រាប់ស្ងួន ចែចង់
២៩	អូគតូច	កំសត់មធ្យម	៣០	អូគធំ	កំសត់មធ្យម

ជ.គណ:កម្មការរៀបចំមហោស្រព

ប្រធាន

គៀង-សគុណា

+

បទកំណាព្យ(សុត្រឬស្មូត)ដែលមានអនិតភាព

ឈ្មោះបទ	ល.រ	បែបបទ	ឈ្មោះបទ	ល.រ	បែបបទ
កាកគតិ	១	ភ្លែកលោតទី១	ព្រហ្មគីតិ	២២	លំនិន
	២	ភ្លែកលោតទី២		២៣	លំនិនបុរាណ
	៣	ភ្លែកបួល		២៤	ពិលាប
	៤	ពិពណ៌នា		២៥	ទំនួញ
	៥	ពិលាប		២៦	អារាធនា(ព្រហ្មជើងក្រែ)
	៦	ទំនួញ		២៧	យោពៅ
	៧	ត្រៃលក្ខណ៍		២៨	សំពៅថយ
	៨	ផ្កាញីមា		២៩	តាសេន
	៩	កាកកាត់ត្រើយ		៣០	កេរកាល
	១០	ភូមិធម៌ភូមិសុខ		៣១	កូនចៅ
	១១	ពុទ្ធបាទប្រាំហាន	ពាក្យ៧	៣២	ពិលាប
ពំនោល	១២	កំហឹង		៣៣	ទំនួញ
	១៣	ទំនួញ		៣៤	ខមាទោស
	១៤	កំសត់		៣៥	មេទ្រីបា
	១៥	កំសត់ខ្លាំង		៣៦	កុមារបា
	១៦	ពោលល្អោនខោល		៣៧	សារភញ្ញ
	១៧	ធម៌យោគ		៣៨	ទំនួញប្រែត
បន្ទោលកាក	១៨	ទំនួញ		៣៩	សាងព្រះភ្នួស
ភុជង្គលីលា	១៩	ទំនួញ		៤០	សិរីមហាមាយា
ឥន្ទ្រជិត	២០	ឥន្ទ្រជិតឬឥន្ទជិត		៤១	អើយក៏
កម្រងកែវ	២១	តាជូរជក់	ពាក្យ៨	៤២	ពិពណ៌នា